ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៤១ សលខ

សារលិខិត

សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ថ្លែងក្នុងឱកាសបើកបវេសនកាលឆ្នាំសិក្សា២០២៦-២០២៧ ថ្ងៃអាទិត្យ ៦រោច ខែអស្សុជ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០ ត្រូវនឹងថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០២៦

- សូមក្រាបថ្វាយបង្គំសម្តេចព្រះមហាសង្ឃរាជទាំងពីរគណៈ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ ជាទីសក្តារៈ
- លោកគ្រូ អ្នកគ្រូ ក្មួយៗសិស្សានុសិស្ស ជាទីស្រឡាញ់
- បងប្អូនជនរួមជាតិ ជាទីស្នេហា!

តាងនាមរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ទូលព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំសូមសម្តែងនូវមនោសញ្ចេតនារីករាយ និងសូមចូលរួមអបអរសាទរថ្ងៃបើកបវេសនកាលឆ្នាំសិក្សាថ្មី២០២៦-២០២៧ ជាមួយលោកគ្រូ អ្នកគ្រូ និងក្មួយៗសិស្សានុសិស្សទាំងអស់នៅទូទាំងព្រះរាជាណាក្រកម្ពុជា។

ថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០២៦ គឺជាថ្ងៃបើកបវេសនកាលឆ្នាំសិក្សាថ្មីដ៏មានអត្ថន័យសម្រាប់ក្មួយៗសិស្សានុសិស្សទូទាំងប្រទេស ជាពិសេសកុមារតូចៗដែលទើបដល់អាយុចូលរៀននៅមត្តេយ្យសិក្សា និងបឋមសិក្សា ព្រមទាំងក្មួយៗដែលបានឡើងថ្នាក់ថ្មី បន្ទាប់ពីបានខិតខំរៀនសូត្រក្នុងឆ្នាំសិក្សាកន្លងមក។ វេលានេះជាឱកាសថ្មីមួយទៀតសម្រាប់ក្មួយៗបន្តសិក្សា ស្វែងយល់ និងកសាងចំណេះដឹង បំណិន និងគុណតម្លៃសម្រាប់អនាគតផ្ទាល់ខ្លួន គ្រួសារ និងសង្គម ដើម្បីចូលរួមអភិវឌ្ឍប្រទេសជាតិឱ្យកាន់តែរីកចម្រើន។

រាជរដ្ឋាភិបាលកម្ពុជា ជានិច្ចកាលតែងតែចាត់ទុក «មនុស្ស» គឺជាធនធានដ៏សំខាន់មិនអាចខ្វះបានសម្រាប់អភិវឌ្ឍសង្គម-សេដ្ឋកិច្ចជាតិ ដោយបានផ្តល់អាទិភាពខ្ពស់ដល់ការអភិវឌ្ឍមូលធនមនុស្សប្រកបដោយចំណេះដឹង ជំនាញ សីលធម៌ វិន័យ សុខភាពផ្លូវកាយនិងផ្លូវចិត្ត ព្រមទាំងសមត្ថភាពក្នុងការសម្របខ្លួនជាមួយនឹងការវិវត្តនៃសង្គម សេដ្ឋកិច្ច និងបច្ចេកវិទ្យា។ ក្នុងន័យនេះ រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា នៅតែបន្តយកចិត្តទុកដាក់ខ្ពស់លើវិស័យអប់រំ តាមរយៈការជំរុញឱ្យសាលារៀនក្លាយជាអង្គភាពផ្តល់សេវាសាធារណៈ ប្រកបដោយប្រសិទ្ធភាពខ្ពស់ អភិបាលកិច្ចល្អ និងមានគណនេយ្យភាពចំពោះប្រជាជននិងសហគមន៍ ដោយពង្រឹងអភិបាលកិច្ចសាលារៀន លើកកម្ពស់សកម្មភាពរៀននិងបង្រៀន និងការអប់រំផ្នែកវិន័យ សីលធម៌ ឥរិយាបថថ្លៃថ្នូរ សក្តិសមជាកុលបុត្រ កុលធីតាខ្មែរ និងជាអ្នកបន្តវេនរបស់ប្រទេសជាតិ។ រាជរដ្ឋាភិបាលនៅតែបន្តអនុវត្តវិធានការគន្លឹះក្នុងវិស័យអប់រំ ដោយផ្តោតលើការពង្រឹងគុណភាពសាលារៀនរដ្ឋ ចាប់ពីមត្តេយ្យសិក្សា

ដល់មធ្យមសិក្សា តាមរយៈ ១) ការពង្រឹងអភិបាលកិច្ចសាលារៀន ២) ការអនុវត្តសកម្មភាពក្រៅម៉ោងសិក្សា ឱ្យស្របទៅតាមតម្រូវការក្នុងការពង្រឹងចំណេះដឹង វិន័យ សីលធម៌ និងឥរិយាបថរបស់សិស្ស ៣) ការយកចិត្តទុកដាក់លើសុខភាពរបស់សិស្ស តាមរយៈកម្មវិធីអាហារូបត្ថម្ភដល់កុមារ និងការត្រួតពិនិត្យគុណភាពចំណីអាហារនៅតាមសាលារៀន និង៤) ការជំរុញ និងលើកទឹកចិត្តឱ្យមានការចូលរួមពីមាតាបិតា អាណាព្យាបាល និងសហគមន៍ ក្នុងការអប់រំស្របតាម៣ក្យស្លោក «ភាពជាដៃគូរដ្ឋនិងសហគមន៍ ដើម្បីការអប់រំ»។ ជាមួយគ្នានេះ សាលារៀនគ្រប់កម្រិតនឹងត្រូវអភិវឌ្ឍស្របតាមស្តង់ដាសាលារៀនគំរូ ដែលមានស្តង់ដាចំនួន៥ គឺ ១) លទ្ធផលសិក្សារបស់សិស្ស ២) ការបង្រៀននិងរៀន ៣) ការចូលរួមរបស់សហគមន៍ ៤) ដំណើរការប្រតិបត្តិនិងរដ្ឋបាលសិក្សា និង៥) គណានេយ្យភាពសាលារៀន។

ឆ្លៀតក្នុងឱកាសនេះ តាងនាមរាជរដ្ឋាភិបាលកម្ពុជា ខ្ញុំសូមកោតសរសើរដល់កិច្ចខិតខំប្រឹងប្រែងរបស់ថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា បុគ្គលិកអប់រំគ្រប់លំដាប់ថ្នាក់ លោកគ្រូ អ្នកគ្រូ ក្នុងការអនុវត្តកំណែទម្រង់វិស័យអប់រំនាពេលកន្លងមក រហូតទទួលបានលទ្ធផលវិជ្ជមានជាបន្តបន្ទាប់ គិតទាំងលទ្ធផលនៃការអប់រំប្រចាំឆ្នាំ ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ព្រមទាំងលទ្ធផលនៃការវាយតម្លៃការសិក្សារបស់សិស្សកម្រិតតំបន់(SEA-PLM 2024) និងកម្រិតអន្តរជាតិ(PISA 2025) គួរជាទីសាទរ។ លទ្ធផលទាំងនេះបានឆ្លុះបញ្ចាំងអំពីការវិវត្តរបស់ប្រព័ន្ធអប់រំកម្ពុជា ដែលផ្តោតជាចម្បងលើការពង្រីកលទ្ធភាពទទួលបានការអប់រំឆ្ពោះទៅរកការលើកកម្ពស់គុណភាព និងលទ្ធផលសិក្សារបស់សិស្ស តាមរយៈការអនុវត្តកំណែទម្រង់ជាបន្តបន្ទាប់ រាប់បញ្ចូលទាំងកំណែទម្រង់សាលារៀន ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កំណែទម្រង់គ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន ការលើកកម្ពស់គុណវុឌ្ឍិនិងការអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀន ការវិនិយោគប្រកបដោយចីរភាពលើអំណាននិងគណិតវិទ្យាថ្នាក់ដំបូង ការលើកកម្ពស់សមធម៌ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងនវានុវត្តន៍ ព្រមទាំងការពង្រឹងការងារអធិការកិច្ច និងប្រព័ន្ធវាយតម្លៃលទ្ធផលសិក្សារបស់សិស្ស។ ដូចនេះ ក្រសួងអប់រំ យុវជន និងកីឡា និងអ្នកពាក់ព័ន្ធទាំងអស់ សូមបន្តអនុវត្ត និងបង្រួបបង្រួមកំណែទម្រង់ទាំងអស់នេះ ខិតខំពង្រីកការអនុវត្តដែលជោគជ័យ និងជានាថា ការកែលម្អការរៀនសូត្រ កើតមាននៅគ្រប់សាលារៀន និងបានដល់សិស្សទាំងអស់នៅទូទាំងប្រទេសកម្ពុជា។

ចំពោះសាលារៀន គ្រូបង្រៀន និងសិស្សានុសិស្សមួយផ្នែកតូច ដែលកំពុងរងផលប៉ះពាល់ដោយសារសង្គ្រាមនៅតាមតំបន់ព្រំដែនកម្ពុជា-ថៃ បន្ថែមលើអន្តរាគមន៍នាពេលកន្លងមក សូមក្រសួងអប់រំ យុវជន និងកីឡា និងអ្នកពាក់ព័ន្ធទាំងអស់ បន្តយកចិត្តទុកដាក់ខ្ពស់ក្នុងការស្តារ និងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធអប់រំ ឱ្យបានឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែង ប្រកបដោយសុវត្ថិភាព អនាម័យ និងគុណភាព។

- **លោកគ្រូ អ្នកគ្រូ ក្មួយៗសិស្សានុសិស្ស ជាទីស្រឡាញ់**
- **បងប្អូនរួមជាតិ ជាទីស្នេហា!**

ដើម្បីឱ្យដំណើរការអប់រំក្នុងឆ្នាំសិក្សាថ្មី២០២៦-២០២៧ ទទួលបានលទ្ធផលកាន់តែល្អប្រសើរ ទូលព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំសូមលើកឡើងនូវចំណុចមួយចំនួនដូចខាងក្រោម៖

ទី១- ក្រសួងអប់រំ យុវជន និងកីឡា ត្រូវបន្តពង្រីកការចុះឈ្មោះចូលរៀននៅគ្រប់កម្រិត និងការរក្សាសិស្សឱ្យបានរៀនសូត្រគង់វង្សរហូតដល់មធ្យមសិក្សា តាមរយៈការពង្រីកនិងសាងសង់សាលារៀនបន្ថែម និងកែលម្អបរិយាកាសសិក្សា ជាពិសេសនៅក្នុងតំបន់ដែលមិនទាន់មានសេវាអប់រំ ការបង្កើតថ្នាក់រៀនបន្ថែម ការបំពាក់មន្ទីរពិសោធន៍ បណ្ណាល័យ និងហេដ្ឋារចនាសម្ព័ន្ធឌីជីថល។

ទី២- ក្រសួងត្រូវបន្តអនុវត្តកំណែទម្រង់សាលារៀនគ្រប់ជ្រុងជ្រោយ ចាប់ពីមត្តេយ្យសិក្សាដល់មធ្យមសិក្សា តាមរយៈការអនុវត្តស្តង់ដាសាលារៀនគំរូ និងបង្កើតប្រព័ន្ធអប់រំដែលស៊ីចង្វាក់គ្នា ដូចជាការអប់រំតាមរយៈការលេងសម្រាប់កុមារនៅមត្តេយ្យសិក្សា ការផ្តោតលើអំណាននិងគណិតវិទ្យាថ្នាក់ដំបូង (EGRA, EGMA) និងការជួយសិស្សរៀនយឺត (PTOM) នៅបឋមសិក្សា ក៏ដូចជាការលើកកម្ពស់វិធីសាស្ត្របង្រៀនថ្មី ដែលផ្តោតលើការអប់រំវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា (STEM) នៅមធ្យមសិក្សា។ ជាមួយគ្នានេះ ត្រូវបន្តសហការជិតស្និទ្ធជាមួយលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិដំរុញការអនុវត្តកំណែទម្រង់ក្នុងវិស័យអប់រំ (គ.វ.អ.) ដើម្បីពង្រឹងប្រសិទ្ធភាព និងចីរភាពនៃការអនុវត្តកម្មវិធីនៅតាមសាលាគោលដៅដែលមានស្រាប់ ស្របតាមបរិបទ និងតម្រូវការជាក់ស្តែង។

ទី៣- ក្រសួងត្រូវបន្តសហការជាមួយអាជ្ញាធររាជធានី-ខេត្ត និងភាគីពាក់ព័ន្ធ ក្នុងការគាំទ្រដល់កុមារ និងសិស្សានុសិស្សដែលបានវិលត្រឡប់ពីប្រទេសថៃ និងសិស្សានុសិស្សដែលកំពុងទទួលសេវាអប់រំនៅតាមជំរំសុវត្ថិភាព ដើម្បីជំរុញនិងសម្របសម្រួលឱ្យពួកគេបានចូលរៀន ឬបន្តការសិក្សាឱ្យបានសមស្របតាមស្ថានភាព និងតម្រូវការជាក់ស្តែង។

ទី៤- ក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវបន្តជំរុញការអនុវត្ត «គន្លងអប់រំថ្មីនៅកម្ពុជា» ដែលរួមមាន : ១) ការផ្តល់ការប្រឹក្សានិងតម្រង់ទិសសិស្សចាប់ពីថ្នាក់ទី៧ និង២) ការអនុវត្តគន្លងវិជ្ជាជីវៈចាប់ពីថ្នាក់ទី១០ និងការបែងចែកគន្លងវិទ្យាសាស្ត្រ និងគន្លងសង្គម នៅថ្នាក់ទី១១ ក្នុងគោលដៅផ្តល់នូវការសិក្សាដែលសមស្របនឹងសមត្ថភាពរបស់សិស្ស និងការត្រៀមខ្លួនសម្រាប់អនាគត។

ទី៥- ក្រសួងត្រូវបន្តធ្វើទំនើបកម្មសៀវភៅសិក្សាចាប់ពីបឋមសិក្សាដល់មធ្យមសិក្សា ដើម្បីពង្រឹងការយល់ដឹងអំពីបញ្ញតិ ការអនុវត្តចំណេះដឹង ការត្រិះរិះពិចារណា ការដោះស្រាយបញ្ហា ហេតុផលវិទ្យាសាស្ត្រ និងសមត្ថភាពសកល រួមជាមួយនឹងការពង្រឹងគ្រឹះរឹងមាំឆ្ពោះទៅក្របខ័ណ្ឌសមត្ថភាពសកល។

ទី៦- ក្រសួងត្រូវបន្តកែទម្រង់ការអប់រំគ្រូបង្រៀន និងពង្រឹងគុណភាពគ្រូបង្រៀន ដោយធ្វើឱ្យប្រសើរឡើងនូវគុណវុឌ្ឍិ និងគរុកោសល្យរបស់គ្រូបង្រៀន ដោយបន្តជ្រើសរើសបេក្ខជនដែលមានសមត្ថភាពខ្ពស់សម្រាប់វិជ្ជាជីវៈបង្រៀន ការអនុវត្តគន្លងអាជីព ការលើកទឹកចិត្ត និងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ ដើម្បីទាក់ទាញ និងរក្សាគ្រូបង្រៀនដែលមានគុណភាពខ្ពស់។ ជាមួយគ្នានេះ គ្រូបង្រៀននៅកម្ពុជាក៏នឹងត្រូវបានបំពាក់បំប៉នដោយជំនាញភាសាបរទេស ជំនាញបច្ចេកវិទ្យាព័ត៌មាន និងទំនាក់ទំនង (ICT) ជំនាញឌីជីថល ជំនាញស្រាវជ្រាវ និងសមត្ថភាពបញ្ញាសិប្បនិម្មិត (AI) ដើម្បីប្រើប្រាស់ក្នុងការបង្រៀន និងការរៀនសូត្របែបទំនើប។

ទី៧- ក្រសួងត្រូវពង្រឹងការត្រួតពិនិត្យ និងពង្រឹងការទទួលខុសត្រូវរបស់សាលារៀន ដោយផ្តោតលើការធ្វើស្វ័យវាយតម្លៃសាលារៀន ការកែលម្អលទ្ធផលសិក្សារបស់សិស្ស ការបង្កើនគុណភាពនៃការបង្រៀន ការលើកកម្ពស់ភាពជាអ្នកដឹកនាំរបស់សាលារៀន និងការសម្រេចបានតាមស្តង់ដាសាលារៀនគំរូ ដើម្បីកំណត់ផ្នែកដែលត្រូវកែលម្អ និងផ្តល់ការគាំទ្រឱ្យចំគោលដៅ។

ទី៨- ក្រសួងត្រូវពង្រឹងការអនុវត្តវាយតម្លៃការសិក្សារបស់សិស្សផ្តោតលើសមត្ថភាព និងពង្រឹងការវាយតម្លៃតាមដំណាក់កាល (formative assessment) ដើម្បីកំណត់គម្លាតចំណេះដឹង និងកែលម្អការបង្រៀនក្នុងថ្នាក់រៀន រួមទាំងការបង្កើតធនាគារសំណួរសម្រាប់វាស់វែងសមត្ថភាពសិស្សលើបំណិនត្រិះរិះពិចារណា ការដោះស្រាយបញ្ហា ហេតុផលវិទ្យាសាស្ត្រ ការអនុវត្តចំណេះដឹង និងសមត្ថភាពសកល។

ទី៩- ក្រសួងត្រូវបន្តយកចិត្តទុកដាក់លើកកម្ពស់ការអប់រំបរិយាបន្ន សម្រាប់កុមារ និងសិស្សដែលមានតម្រូវការពិសេស ឬស្ថិតក្នុងស្ថានភាពងាយរងគ្រោះ តាមរយៈការផ្តល់ការគាំទ្រ និងសម្របសម្រួលចាំបាច់ និងមានប្រសិទ្ធភាព។

ទី១០- ក្រសួងត្រូវបន្តលើកកម្ពស់ការអប់រំឌីជីថល តាមរយៈការកែលម្អវេទិកាឌីជីថល និងបង្កើតមជ្ឈមណ្ឌលអប់រំឌីជីថល ការផលិតវីដេអូបង្រៀនមុខវិជ្ជាគោល និងសម្រាប់ថ្នាក់ប្រឡងការបញ្ចូលបច្ចេកវិទ្យាឌីជីថលទៅក្នុងការរៀននិងបង្រៀន ការបង្កើតកម្មវិធីអប់រំឌីជីថល ឆ្លើយតបនឹងតម្រូវការទីផ្សារការងារ ការអភិវឌ្ឍសង្គម សេដ្ឋកិច្ចជាតិ បរិវត្តកម្មបច្ចេកវិទ្យា ការផ្លាស់ប្តូរនិម្មាបនកម្មសកល ក្នុងគោលដៅកសាងពលរដ្ឋឌីជីថល និងបង្កើនសមត្ថភាពសិស្ស និស្សិតលើវិស័យឌីជីថល។

ទី១១- គ្រឹះស្ថានសិក្សាគ្រប់កម្រិត ត្រូវពង្រឹងតួនាទីនិងការទទួលខុសត្រូវរបស់គណៈគ្រប់គ្រងសាលារៀន និងគ្រូបង្រៀន ក្នុងការដឹកនាំនិងគ្រប់គ្រងសាលារៀនឱ្យមានប្រសិទ្ធភាព និងគណនេយ្យភាព។ នាយកសាលា និងគ្រូបង្រៀន ត្រូវប្រកាន់ខ្ជាប់វិន័យការងារ ដោយមកដល់សាលាមុនសិស្ស និងចេញពីសាលាក្រោយសិស្ស ព្រមទាំងតាមដាននិងដោះស្រាយបាតុភាពនានា ទាំងនៅក្នុងនិងជុំវិញសាលារៀន ដោយសហការជាមួយមាតាបិតា អាណាព្យាបាល សហគមន៍ និងអាជ្ញាធរដែនដី ដើម្បីលើកកម្ពស់វិន័យ សីលធម៌ និងសុវត្ថិភាពក្នុងការសិក្សា។ ទន្ទឹមនឹងនេះ យើងទាំងអស់គ្នាត្រូវចូលរួមលើកកម្ពស់កិត្តិយស និងសេចក្តីថ្លៃថ្នូរនៃវិជ្ជាជីវៈគ្រូបង្រៀន និងធ្វើជាគំរូល្អសម្រាប់សិស្សានុសិស្ស និងសង្គមជាតិ។

ទី១២- គ្រឹះស្ថានសិក្សាគ្រប់កម្រិត ត្រូវបន្តយកចិត្តទុកដាក់លើកកម្ពស់អនាម័យ សុខភាព សុវត្ថិភាព និងបរិស្ថានសិក្សាប្រកបដោយភាពស្អាត បៃតង និងមានអនាម័យល្អ តាមរយៈការពង្រឹងការអប់រំសុខភាព ការរៀបចំបន្ទប់សុខភាពតាមស្តង់ដា ការធានាបាននូវសុវត្ថិភាពចំណីអាហារ និងអាហារូបត្ថម្ភ ព្រមទាំងការគ្រប់គ្រងសំរាម និងបរិស្ថានសាលារៀនឱ្យបានល្អប្រសើរ។ ទន្ទឹមនេះ ត្រូវរៀបចំសាលារៀនឱ្យមានភាពធន់នឹងផលប៉ះពាល់នៃបម្រែបម្រួលអាកាសធាតុ និងគ្រោះមហន្តរាយ ព្រមទាំងយកចិត្តទុកដាក់លើសុខភាពផ្លូវចិត្ត និងសុខុមាលភាពរបស់គ្រូបង្រៀន និងសិស្សានុសិស្ស ដើម្បីបង្កើតបរិយាកាសសិក្សាប្រកបដោយសុវត្ថិភាព សុខភាព ល្អ និងអំណោយផលដល់ការរៀនសូត្រ។

ទី១៣- មាតាបិតា និងអាណាព្យាបាលគ្រប់រូប សូមយកចិត្តទុកដាក់ជំរុញ និងគាំទ្រកូនចៅឱ្យចុះឈ្មោះចូលរៀនជាប្រចាំ ព្រមទាំងចូលរួមតាមដានការសិក្សា អត្តចរិត សីលធម៌ សុជីវធម៌ និងឥរិយាបថរបស់កូនចៅ ទាំងនៅក្នុងគ្រួសារ និងសហគមន៍។ ទន្ទឹមនេះ សូមបង្កើតបរិយាកាសសិក្សាល្អនៅក្នុងគ្រួសារ ជួយកូនចៅរៀនសូត្របន្ថែមនៅផ្ទះ និងលើកទឹកចិត្តឱ្យមានទម្លាប់អានសៀវភៅជាប្រចាំ ដោយចំណាយពេលអាន និងពិភាក្សាជាមួយកូនចៅ ដើម្បីពង្រឹងចំណេះដឹងជំនាញគិត និងទម្លាប់សិក្សាដោយខ្លួនឯង។ ក្នុងបរិបទឌីជីថល សូមចូលរួមណែនាំ និងតាមដានការប្រើប្រាស់បច្ចេកវិទ្យា និងបណ្តាញសង្គមរបស់កូនចៅឱ្យបានសមស្រប មានសុវត្ថិភាព និងផ្តល់ប្រយោជន៍ដល់ការសិក្សា និងការអភិវឌ្ឍ។

ទី១៤- ក្មួយៗសិស្សានុសិស្ស យុវជន និងយុវនារីទាំងអស់ សូមបន្តខិតខំរៀនសូត្រ ស្រាវជ្រាវ និងអភិវឌ្ឍខ្លួនជាប្រចាំ ដោយផ្តោតលើការអភិវឌ្ឍវិជ្ជាសម្បទា បំណិនសម្បទា កាយសម្បទា និងចរិយាសម្បទា ដើម្បីក្លាយជាមូលធនមនុស្សប្រកបដោយសមត្ថភាព និងទំនួលខុសត្រូវ។ សូមក្មួយៗស្រឡាញ់ និងថែរក្សាខ្លួន ស្រឡាញ់គ្រួសារ មានវិន័យ និងចៀសឱ្យឆ្ងាយពីគ្រឿងញៀន អំពើអបាយមុខ និងអំពើអវិជ្ជមានគ្រប់រូបភាព ដើម្បីកសាងអនាគតដ៏ភ្លឺស្វាងសម្រាប់ខ្លួនឯង គ្រួសារ និងប្រទេសជាតិ។

ទី១៥- គ្រប់ក្រសួង ស្ថាប័ន អាជ្ញាធរគ្រប់លំដាប់ថ្នាក់ វិស័យឯកជន សង្គមស៊ីវិល និងដៃគូអភិវឌ្ឍជាតិ-អន្តរជាតិ សូមបន្តនិងបង្កើនការចូលរួមជាមួយរាជរដ្ឋាភិបាល និងក្រសួងអប់រំ យុវជន និងកីឡា ក្នុងការអភិវឌ្ឍនិងការពង្រឹងមូលធនមនុស្សនៅកម្ពុជា ស្របតាមតម្រូវការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច និងអនាគតប្រទេសជាតិ។

ទី១៦- គ្រប់ស្ថានីយវិទ្យុ ទូរទស្សន៍របស់រដ្ឋ និងឯកជន ព្រមទាំងប្រព័ន្ធផ្សព្វផ្សាយគ្រប់រូបភាព សូមបន្តចូលរួមផ្សព្វផ្សាយឱ្យបានទូលំទូលាយអំពីសារៈសំខាន់នៃការអប់រំ ការប្រមូលកុមារចូលរៀន និងការរៀនសូត្រពេញមួយជីវិត ព្រមទាំងជំរុញការផលិត និងផ្សព្វផ្សាយមាតិកាអប់រំ ធនធានសិក្សាឌីជីថល និងវីដេអូបង្រៀនប្រកបដោយគុណភាព ដើម្បីពង្រីកឱកាសទទួលបានការអប់រំឱ្យបានទូលំទូលាយ គ្រប់ទីកន្លែង និងគ្រប់ពេលវេលា។

ជាថ្មីម្តងទៀត ទូលព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំសូមថ្លែងអំណរព្រះគុណចំពោះព្រះតេជគុណ ព្រះសង្ឃគ្រប់ព្រះអង្គ សូមអរគុណចំពោះបងប្អូនជនរួមជាតិ លោកគ្រូ អ្នកគ្រូ និងបុគ្គលិកអប់រំទាំងអស់ ព្រមទាំងដៃគូអភិវឌ្ឍ វិស័យឯកជន អង្គការមិនមែនរដ្ឋាភិបាល និងសប្បុរសជននានា ដែលតែងតែគាំទ្រនិងរួមចំណែកក្នុងការកសាង និងអភិវឌ្ឍវិស័យអប់រំនៅកម្ពុជា ឱ្យមានដំណើរការរីកចម្រើនគួរជាទីមោទនៈ ក្នុងរយៈកាលកន្លងមកនេះ និងសូមបន្តជួយឧបត្ថម្ភគាំទ្រ និងផ្តល់កិច្চសហការល្អតទៅទៀត ដើម្បីបុព្វហេតុនៃការអភិវឌ្ឍកុមារនិងយុវជនកម្ពុជាគ្រប់ៗរូប។

ជាទីបញ្ចប់ ក្នុងឱកាសបើកបវេសនកាលឆ្នាំសិក្សាថ្មី២០២៦-២០២៧ នេះ ទូលព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំសូមថ្វាយនិងប្រគេនពរព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ និងសូមជូនពរសម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រី លោកគ្រូ អ្នកគ្រូ មាតាបិតា អាណាព្យាបាល ប្អូនៗ ក្មួយៗសិស្សានុសិស្ស និងជនរួមជាតិទាំងអស់ សូមបានប្រកបដោយពុទ្ធពរទាំង៤ប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូមអរព្រះគុណនិងអរគុណ!

ថ្ងៃចន្ទ ១៥កើត ខែអស្សុជ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០
រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២៦

ឆ្លាយករដ្ឋមន្ត្រី

សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត